## រឿងទី៦៖ លោកមេទ័ពណាម៉ាន់

**ខគម្ពីរ៖ ២ពង្សាវតាក្សត្រ៥៖១៤**

លោកណាម៉ាន់ក៏ចុះទៅក្នុងទន្លេយ័រដាន់ ហើយមុជក្នុងទឹកចំនួនប្រាំពីរដង តាមពាក្យដែលអ្នកជំនិតរបស់ព្រះជាម្ចាស់បានប្រាប់ ស្រាប់តែសាច់របស់លោកឡើងស្អាត ដូចសាច់កូនក្មេង លោកក៏ជាស្អាតបរិសុទ្ធ។

នៅជិតស្រុកអ៊ីស្រាអែលមានស្រុកមួយឈ្មោះថាស៊ីរី។ នៅស្រុកមានមេទ័ពដ៏ខ្ពង់ខ្ពស់ម្នាក់ឈ្មោះថាណាម៉ាន់។
ស្តេចស្រុកស៊ីរីស្រឡាញ់លោកមេទ័ពណាម៉ាន់ណាស់។ មេទ័ពណាម៉ាន់នោះបានកើតជំងឺឃ្លង់មើលមិនជា។
ជំងឺឃ្លង់គឺជាជំងឺដ៏គួរឱ្យខ្លាចជាទីបំផុត ពេលដែលកើតវាហើយ វានឹងធ្វើឱ្យលែងមានអារម្មណ៍អ្វីទាំងអស់ ទោះបី ម្រាមដៃម្រាមជើងរលួយផ្អុះសាច់មកយ៉ាងណាក៏មិនមានអារម្មណ៍ថាឈឺដែរ។ នៅក្នុងផ្ទះរបស់ណាម៉ាន់ មានក្មេងស្រីបម្រើម្នាក់ដែលត្រូវបានគេចាប់មកពីស្រុកអ៊ីស្រាអែល។
ក្មេងស្រីនោះជាអ្នកដែលជឿព្រះជាម្ចាស់។
ថ្ងៃមួយ ក្មេងស្រីនោះ បាននិយាយទៅកាន់ភរិយារបស់មេទ័ពណាម៉ាន់ថា៖
«បើលោកមេទ័ពណាម៉ាន់ទៅជួបលោកអេលីសេដែលកំពុងរស់នៅក្នុងស្រុកកំណើតខ្ញុំ នោះលោកនឹងអាចជាពីជំងឺ ឃ្លង់នេះបានជាមិនខាន»។
ភរិយារបស់ណាម៉ាន់ បានយកពាក្យសម្ដីក្មេងស្រីនោះទៅប្រាប់ស្វាមី។ មេទ័ពណាម៉ាន់ ក៏បានធ្វើដំណើរចេញទៅស្រុកអ៊ីស្រាអែលភ្លាម។
មេទ័ពណាម៉ាន់ បានចេញទៅជាមួយនឹងអំណោយជាច្រើនសម្រាប់ជូនដល់ព្យាការីអេលីសេ។
ទីបំផុត មេទ័ពណាម៉ាន់ និងអ្នកបម្រើក៏បានទៅដល់ផ្ទះរបស់ព្យាការីអេលីសេ។
ប៉ុន្តែ មិនឃើញព្យាការីអេលីសេចេញមកទេ ឃើញតែអ្នកបម្រើចេញមកនាំពាក្យព្យាការីអេលីសេមកប្រាប់លោកថា៖
«សូមលោកអញ្ជើញទៅទន្លេយ័រដាន់ ហើយមុជទឹកឱ្យបានចំនួនប្រាំពីរដងចុះ នោះស្បែកលោកនិងជាសះស្បើយជា មិនខាន»។
មេទ័ពណាម៉ាន់មានការខឹងសម្បារជាខ្លាំង។ ប៉ុន្តែអ្នកបម្រើលោកបាននិយាយទៅលោកថា៖
«លោកមេទ័ព បើគ្រាន់តែទៅមុជទឹកនៅទន្លេយ័រដាន់ចំនួនប្រាំពីរដង វាមិនមែនជារឿងពិបាកទេ។ យើងខំមកពីឆ្ងាយ ហើយ យល់ល្អ យើងគួរសាកទៅសិនទៅ»។
មេទ័ពណាម៉ាន់ ស្តាប់តាមអ្នកបម្រើក៏ធ្វើដំណើរទៅទន្លេយ័រដាន់។
មេទ័ពណាម៉ាន់បានជ្រមុជខ្លួនបានមួយដង ពីរដង បីដង រហូតដល់ប្រាំមួយដងហើយ ប៉ុន្តែគ្មានអ្វីខុសប្លែកសោះ។
ប៉ុន្តែ ដល់ជ្រមុជលើកទីប្រាំពីរ ស្រាប់តែការដ៏គួរឱ្យភ្ញាក់ផ្អើលក៏បានកើតឡើង។
ជំងឺឃ្លង់នៅលើខ្លួនរបស់មេទ័ពណាម៉ានក៏បានជាសះស្បើយ របួសទាំងអស់ក៏បានជា សាច់ដែលធ្លាប់មានខ្ទុះ ក៏ចាប់ផុះសាច់ថ្មីឡើងមក។
តាមរយៈការនេះ មេទ័ពណាម៉ាន់បានប្រែក្លាយជាមនុស្សដែលជឿលើព្រះជាម្ចាស់យ៉ាងខ្ជាប់ខ្ជួន។





**សកម្មភាពទី១**

សូមធ្វើតាមលំដាប់លំដោយដូចខាងក្រោម។

1. សូមកាត់កន្លែងដែលបានសម្គាល់នៅចំកណ្ដាលទន្លេ។ 2. សូមកាត់រូបលោកមេទ័ពណាម៉ាន់ដែលកើតឃ្លង់ និងរូបលោកមេទ័ពណាម៉ាន់ដែលបានជាសះស្បើយ រួចយកទៅបិទភ្ជាប់លើដងកាវ៉ម។ 3. ធ្វើដូចជារឿងដែលបានរៀននៅថ្ងៃនេះ ដោយដាក់រូបលោកមេទ័ពណាម៉ាន់ដែលកើតឃ្លង់ទៅក្នុងទន្លេ បន្ទាប់ពីធ្វើចលនាជ្រមុជងើបៗចំនួនប្រាំពីរដងរួច សូមផ្លាស់ប្ដូរទៅជារូបលោកមេទ័ពណាម៉ាន់ដែលបានជាសះស្បើយវិញ។

សម្ភារៈ៖ កាវ, កន្ត្រៃ, ដងកាវ៉ម ២



សកម្មភាពទី២ សូមឆ្លើយសំណួរខាងក្រោម។

a. តើនរណាជាអ្នកប្រាប់លោកមេទ័ពណាម៉ាន់អំពីវិធីដែលអាចព្យាបាលជំងឺឃ្លង់?

---

b. តើនរណាជាអ្នកបញ្ចុះបញ្ចូលលោកមេទ័ពណាម៉ាន់ឱ្យផ្លាស់ប្តូរគំនិត?

---

c. តើលោកមេទ័ពណាម៉ាន់បានធ្វើអ្វីខ្លះបន្ទាប់ពីបានជាសះស្បើយពីជំងឺ?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (២ពង្សាវតាក្សត្រ៥:១៤)

> លោកណាម៉ាន់ក៏ចុះទៅក្នុងទន្លេយ័រដាន់ ហើយមុជក្នុងទឹកចំនួនប្រាំពីរដង តាមពាក្យដែលអ្នកជំនិតរបស់ព្រះជាម្ចាស់បានប្រាប់